ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

CAMBODIA
Kingdom of Wonder
feel the warmth

ក្រសួងទេសចរណ៍
លេខ ០០១ ទស.ណន

ថ្ងៃ សុក្រ ៣កើត ខែ មាឃ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២១

# សារាចរណែនាំ
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធចុះបញ្ជីឈ្មោះភ្ញៀវទេសចរតាមប្រព័ន្ធ Telegram BOT ដល់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ទូទាំងប្រទេស

អនុវត្តតាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ (Covid-19) នាពេលបច្ចុប្បន្ន និងដើម្បីផ្តល់ភាពងាយស្រួលចំពោះការស្វែងរកអ្នកប៉ះពាល់ដោយប្រយោល និងដោយផ្ទាល់ក្នុងករណីរកឃើញថាមានអ្នកឆ្លងក្នុងមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍។

ក្រសួងទេសចរណ៍ សូមស្នើដល់ អ្នកឧកញ៉ា លោកឧកញ៉ា ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានសមាគមក្នុងឧស្សាហកម្មទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដូចខាងក្រោម៖

១. គ្រប់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់ទូទាំងប្រទេសមានកាតព្វកិច្ចចូលរួមរៀបចំ និងប្រើប្រាស់ប្រព័ន្ធចុះបញ្ជីឈ្មោះភ្ញៀវទេសចរតាមប្រព័ន្ធ Telegram BOT ជាទម្រង់រួមមួយ ដែលផលិតដោយក្រសួងទេសចរណ៍

២. គ្រប់សមាគមក្នុងឧស្សាហកម្មទេសចរណ៍ត្រូវចូលរួមសហការជាមួយក្រសួងទេសចរណ៍ជម្រុញដល់សមាជិករបស់ខ្លួនចូលរួមប្រើប្រាស់ប្រព័ន្ធចុះបញ្ជីឈ្មោះភ្ញៀវទេសចរតាមប្រព័ន្ធ Telegram BOT

៣. គ្រប់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ទាំងអស់ទូទាំងប្រទេសមានកាតព្វកិច្ចរៀបចំដាក់តាំងបង្ហាញស្ទិកគ័រប្រព័ន្ធចុះបញ្ជីឈ្មោះភ្ញៀវទេសចរតាមប្រព័ន្ធ Telegram BOT នៅតាមច្រកចេញចូលមូលដ្ឋានអាជីវកម្ម លើតុអាហារ ឬកន្លែងដែលផ្តល់ភាពងាយស្រួលដល់ភ្ញៀវទេសចរប្រើប្រាស់

៤. មន្ទីរទេសចរណ៍រាជធានី-ខេត្តទាំង២៥ មានកាតព្វកិច្ចសហការជាមួយរដ្ឋបាលរាជធានី-ខេត្ត ដើម្បីចុះជម្រុញ និងតាមដានការអនុវត្តប្រព័ន្ធចុះបញ្ជីឈ្មោះភ្ញៀវទេសចរតាមប្រព័ន្ធ Telegram BOT របស់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

៥. មន្ទីរទេសចរណ៍រាជធានី-ខេត្ត និងសមាគមក្នុងឧស្សាហកម្មទេសចរណ៍ត្រូវធ្វើរបាយការណ៍បច្ចុប្បន្នអំពីការអនុវត្តរបស់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ ឬសមាជិករបស់ខ្លួនមកក្រសួងទេសចរណ៍ជារៀងរាល់ខែ (យ៉ាងយូរសប្តាហ៍ទី០១ នៃខែបន្ទាប់)។

ទទួលបានសារាចរណែនាំនេះ សូម អ្នកឧកញ៉ា លោកឧកញ៉ា ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានសមាគមក្នុងឧស្សាហកម្មទេសចរណ៍ ប្រតិបត្តិករទេសចរណ៍ និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ចូលរួមអនុវត្តប្រព័ន្ធចុះបញ្ជីឈ្មោះភ្ញៀវទេសចរតាមប្រព័ន្ធ Telegram BOT នេះ ឱ្យមានប្រសិទ្ធភាពរហូតដល់ស្ថានភាពជំងឺកូវីដ-១៩ត្រូវបានបញ្ចប់ទាំងស្រុង។

**រដ្ឋមន្ត្រី**

**ថោង ខុន**

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩
  "ដើម្បីជូនជ្រាប"
- រដ្ឋបាលរាជធានី-ខេត្ត
  "ដើម្បីចូលរួមអនុវត្ត"
- មន្ទីរទេសចរណ៍រាជធានី-ខេត្ត
  "ដើម្បីអនុវត្ត"
- សមាគមក្នុងឧស្សាហកម្មទេសចរណ៍
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ